# សេចក្តីថ្លែងការណ៍រួម

## សង្គមស៊ីវិលសំដែងការព្រួយបារម្ភចំពោះការផ្តល់សម្បទានដីសេដ្ឋកិច្ចដោយមិនស្របនឹងច្បាប់

សម្ព័ន្ធ នៃ អង្គការមិនមែនរដ្ឋាភិបាល រួមមាន គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិកម្ពុជា (CHRAC) វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum) និងក្រុមការងារពិសេសសិទ្ធិលំនៅដ្ឋាន (HRTF) សូមសំដែងនូវការខកចិត្ត និងការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលនាពេលកន្លងមកបានផ្តល់សម្បទានដីសេដ្ឋកិច្ចដល់ក្រុមហ៊ុនឯកជនជាច្រើនដោយមិនស្របនឹងច្បាប់ភូមិបាល និង ស្មារតីនៃអនុក្រឹត្យស្តីពីសម្បទានសេដ្ឋកិច្ច លេខ១៤៦ ។

មកដល់ពេលនេះ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សម្បទានដីសេដ្ឋកិច្ចឱ្យក្រុមហ៊ុនឯកជនជាច្រើន ដែលក្នុងនោះមានទាំងក្រុមហ៊ុនក្នុងស្រុក និងក្រុមហ៊ុនបរទេសផងដែរ។ ជាការកត់សំគាល់នាពេលកន្លងមក គឺថា រាជរដ្ឋាភិបាលកម្ពុជាភាគច្រើនបានធ្វើការផ្តល់សម្បទានដីសេដ្ឋកិច្ចដោយមិនស្របទៅនឹងស្មារតីនៃច្បាប់ភូមិបាល ដោយសារតែរាជរដ្ឋាភិបាល បានផ្តល់សម្បទានដីសេដ្ឋកិច្ចឱ្យទៅក្រុមហ៊ុន ដែលមានម្ចាស់កម្មសិទ្ធិជារូបវន្តបុគ្គលតែមួយ មានចំនួនលើសពី ១០,០០០ហិកតា ដែលចំនួនលើសនេះត្រូវហាមឃាត់ដោយមាត្រា៥៩ នៃ ច្បាប់ភូមិបាល ដែលចែងថា "*សម្បទានដីមានទំហំច្រើនបំផុតត្រឹមតែ ១០,០០០ (មួយម៉ឺន) ហិកតា។...*" នៅក្នុងករណីខ្លះទៀត យើងក៏បានរកឃើញថាមានការផ្តល់ដីសម្បទានសេដ្ឋកិច្ចច្រើនកន្លែងឱ្យទៅក្រុមហ៊ុនផ្សេងៗ តែគ្រប់គ្រងដោយរូបវន្តបុគ្គលតែម្នាក់មានលើសពីចំនួន ១០,០០០ (មួយម៉ឺន) ហិកតា។

ទន្ទឹមនឹងការផ្តល់សម្បទានដីលើសទំហំដែលមានចែងនៅក្នុងច្បាប់ភូមិបាល យើងក៏កត់សំគាល់ឃើញទៀតថាការផ្តល់ទាំងនោះ មិនស្របនឹងអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ចលេខ១៤៦ផងដែរ ជាពិសេសមាត្រា ៤ នៃអនុក្រិត្យនេះ ដូចជា ការខកខានមិនបានធ្វើការសិក្សាអំពីផលប៉ះពាល់ខាងបរិស្ថាន និងសង្គមជាសាធារណៈ និងការពិគ្រោះយោបល់ជាសាធារណៈជាមួយប្រជាពលរដ្ឋពាក់ព័ន្ធឱ្យបានល្អិតល្អន់ជាមុន និង ការមិនបានដោះស្រាយបញ្ហាដែលពាក់ព័ន្ធជាមួយប្រជាពលរដ្ឋជាមុន ជាដើម។

ខាងក្រោមនេះ គឺជាករណីសំខាន់ៗទាក់ទិននឹងការផ្តល់ដីសម្បទានសេដ្ឋកិច្ចដោយរាជរដ្ឋាភិបាលកម្ពុជាទៅឱ្យក្រុមហ៊ុនមួយចំនួន ដែលសម្ព័ន្ធ នៃ អង្គការសង្គមស៊ីវិល បានធ្វើការស៊ើបអង្កេតឃ្លាំមើល នាពេលកន្លងមកនេះ ជាឧទាហរណ៍ជាក់ស្តែងឃើញថា រាជរដ្ឋាភិបាលបានផ្តល់សម្បទានដីសេដ្ឋកិច្ចដល់ក្រុមហ៊ុនបី ដែលគ្រប់គ្រងដោយបុគ្គលតែម្នាក់ គឺៈ

១- នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៦ ក្រុមហ៊ុន កោះកុងស៊ូហ្គើរ អ៊ិនដាសស្ទ្រី បានទទួលដីសម្បទានទំហំ ៩,៧០០ហិកតា នៅក្នុងស្រុកស្រែអំបិល ខេត្តកោះកុង។ ដីសម្បទាននេះ ក៏កំពុងមានទំនាស់ជាមួយប្រជាពលរដ្ឋចំនួន ៤០០គ្រួសារ។

២- នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ ទីស្តីការគណៈរដ្ឋមន្ត្រី បានចេញ សជណ លេខ១៤៧៥ សំរេចអនុញ្ញាតឱ្យវិនិយោគដាំអំពៅ ដោយក្រុមហ៊ុនចំនួន៣ គឺៈ ទី១- ក្រុមហ៊ុន អង្គរស៊ូហ្គើរ ចំនួន ៩,៨៦៣ ហិកតា ទី២- ក្រុមហ៊ុន (ខេមបូឌា) ខានអេន ស៊ូហ្គើរ វ៉ែលលី មានចំនួន ១០,៩២៥ ហិកតា និង ទី៣ - ក្រុមហ៊ុនទន្លេស៊ូហ្គើរ ខេន ចំនួន ១២,១៦៧ ហិកតា។

៣- នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១០ រាជរដ្ឋាភិបាលបានសំរេចតាមរយៈ សជណ លេខ១៧៤ ផ្តល់ដីសម្បទានឱ្យក្រុមហ៊ុនភ្នំពេញស៊ូហ្គើរចំនួន៨,៣៤៣ ហិកតា នៅក្នុងឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។

ដូចនេះ បើយោងតាមឯកសារដីសម្បទានសេដ្ឋកិច្ច និងការសិក្សាស្រាវជ្រាវ បានបង្ហាញជូនខាងលើ ឃើញថាមានក្រុមហ៊ុនចំនួន៣ ដែលមានឈ្មោះ ទី១-"ក្រុមហ៊ុនកោះកុងស៊ូហ្គើរ អ៊ិនដាសស្ទ្រី", ទី២- "ក្រុមហ៊ុនអង្គរស៊ូហ្គើរ" និង ទី៣ "ក្រុមហ៊ុនភ្នំពេញស៊ូហ្គើរ" ជាក្រុមហ៊ុន ដែលគ្រប់គ្រងដោយរូបវន្តបុគ្គលតែម្នាក់។ ដូចនេះ ការផ្តល់សម្បទានដីសេដ្ឋកិច្ចចំពោះករណីបែបនេះ គឺជាការផ្តល់សម្បទានផ្ទុយនឹងមាត្រា៥៩ នៃច្បាប់ភូមិបាល ហើយ។

ក្នុងនាមជាសម្ព័ន្ធ នៃ អង្គការសង្គមស៊ីវិល សូមស្វាគមន៍ចំពោះការយកចិត្តទុកដាក់ របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការទាក់ទាញក្រុមហ៊ុនវិនិយោគនានា ដើម្បីចូលរួមចំណែកក្នុងកិច្ចអភិវឌ្ឍន៍ប្រទេសជាតិ តាមរយៈការធ្វើសម្បទានដីសេដ្ឋកិច្ច។ ប៉ុន្តែទន្ទឹមនឹងនេះដែរ យើងក៏មានការសោកស្តាយ និងបដិសេធដាច់ខាតចំពោះការផ្តល់សម្បទានដីសេដ្ឋកិច្ចណា ដែលផ្ទុយនឹងច្បាប់ និងរំលោភសិទ្ធិមនុស្ស ពីព្រោះថា ការផ្តល់ដីសម្បទានសេដ្ឋកិច្ចនេះ មិនចូលរួមក្នុងកិច្ចអភិវឌ្ឍន៍ប្រទេសជាតិប្រកបចីរភាពនោះទេ ហើយ វាក៏អាចធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានដល់ក្រុមហ៊ុនផ្សេងៗទៀតដែលគោរពច្បាប់ត្រឹមត្រូវ មិនហ៊ានចូលមកធ្វើការវិនិយោគប្រទេសកម្ពុជាយើង។

ដូចនេះ សម្ព័ន្ធ នៃអង្គការសង្គមស៊ីវិល សូមផ្តល់ជូននូវអនុសាសន៍មួយចំនួន ជូនដល់រាជរដ្ឋាភិបាលកម្ពុជាមេត្តា ធ្វើការពិចារណា ដូចខាងក្រោមនេះ :

១- សូមបញ្ឈប់ជាបណ្តោះអាសន្នចំពោះការផ្តល់ដី សម្បទានដីសេដ្ឋកិច្ចថ្មី រហូតដល់រដ្ឋាភិបាលអាចធានាបាននូវការការពារ និងគោរពតាមវិធានច្បាប់ត្រឹមត្រូវ។

២- ត្រូវបន្តពិនិត្យឡើងវិញ រាល់ដីសម្បទានសេដ្ឋកិច្ចដែលមានស្រាប់ ហើយ ដីសម្បទានសេដ្ឋកិច្ចណាដែលបានផ្តល់ដោយមិនស្របច្បាប់ ត្រូវតែលុបចោល ។ រាល់ការពិនិត្យឡើងវិញ គួរតែធ្វើជាសាធារណៈ ។

៣- រាល់ព័ត៌មានអំពីការផ្តល់សម្បទានដីសេដ្ឋកិច្ច គួរតែមានការផ្សព្វផ្សាយជាសាធារណៈ ឬធ្វើបច្ចុប្បន្នភាពនៅលើគេហទំព័រ( Website) របស់រាជរដ្ឋាភិបាល។

៤- ស្នើកាត់ចេញនូវដីធ្លីណាដែលមានវិវាទពាក់ព័ន្ធជាមួយប្រជាពលរដ្ឋ និងប្រគល់ជូនទៅប្រជាពលរដ្ឋវិញ និង ជំរុញឱ្យសមត្ថកិច្ចពាក់ព័ន្ធ ធ្វើការដោះស្រាយដីជូនប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ពីការផ្តល់ដីសម្បទាន ឱ្យបានឆាប់រហ័សមុននឹងអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើសកម្មភាពរបស់ខ្លួន។

៥- គួរជំរុញឱ្យក្រុមហ៊ុនផ្តល់បច្ចេកវិទ្យា និងធនធាន ទៅដល់ប្រជាពលរដ្ឋយើង ក្នុងការដាំដំណាំនានា ដែល ជាតំរូវការផ្នែកវត្ថុធាតុដើម របស់ក្រុមហ៊ុន។

*ភ្នំពេញ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១០*

**សំរាប់ព័ត៌មានបន្ថែមសូមទាក់ទង:**

| | | |
|---|---|---|
| លោក **សុក សំអឿន** | ប្រធានសំរបសំរួលស្តីទី នៃគណៈកម្មាធិការប្រព្រឹត្តិកម្ម (CHRAC) និងជា | |
| | នាយកប្រតិបត្តិ អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) | ទូរស័ព្ទលេខ: ០១២ ៩០១ ១៩៩ |
| លោក **ធន សារាយ** | ប្រធានសមាគមអាដហុក (ADHOC) | ទូរស័ព្ទលេខ: ០១៦ ៨៨០ ៥០៩ |
| លោក **ឈិត សំអាត** | នាយកប្រតិបត្តិ NGO Forum | ទូរស័ព្ទលេខ: ០១២ ៩២៨ ៥៨៥ |
| លោក **សៀ ភារម្យ** | នាយកលេខាធិការដ្ឋាន ក្រុមការងារពិសេសសិទ្ធិលំនៅដ្ឋាន (HRTF) | ទូរស័ព្ទលេខ: ០១២ ៨៥២ ៣២៥ |